ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន
MINISTRY OF INFORMATION

ក្រសួងព័ត៌មាន

លេខ៖ ....៧២០.សជណ.... ព.ម.

# សេចក្ដីជូនដំណឹង
## ស្ដីពីការបើកដំណើរការទទួលចុះឈ្មោះអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ សម្រាប់កិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ នៅព្រះរាជាណាចក្រកម្ពុជា

ក្រសួងព័ត៌មាន មានកិត្តិយសសូមជម្រាបជូនដល់អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ មេត្តាជ្រាបថា ព្រះរាជាណាចក្រកម្ពុជានឹងរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ និងសន្និសីទថ្នាក់រដ្ឋមន្ត្រីហ្វ្រង់កូហ្វូនីលើកទី៤៨ ដែលនឹងប្រព្រឹត្តធ្វើចាប់ពីថ្ងៃទី១៤ ដល់ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៦ នៅរាជធានីភ្នំពេញ។

ក្រសួងព័ត៌មានបានចាប់ផ្តើមបើកដំណើរការការទទួលចុះឈ្មោះអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ដែលមានបំណងចូលរួមយកព័ត៌មាន និងផ្សព្វផ្សាយអំពីកិច្ចដំណើរការនិងលទ្ធផលនៃកិច្ចប្រជុំកំពូលខាងលើ តាមរយៈគេហទំព័រផ្លូវការ http://mediafrancophonie2026.inb.gov.kh ឬតាមរយៈ QR Code ខាងក្រោម ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៦។

ក្រសួងព័ត៌មាន រង់ចាំទទួលស្វាគមន៍អ្នកសារព័ត៌មានជាតិ និងអន្តរជាតិទាំងអស់ ដោយក្តីសោមនស្ស សម្រាប់ការអញ្ជើញមកចូលរួមយកព័ត៌មាន និងផ្សព្វផ្សាយក្នុងព្រឹត្តិការណ៍កិច្ចប្រជុំកំពូលជាប្រវត្តិសាស្ត្រនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ជ្រាបជាព័ត៌មាន៕

ថ្ងៃសុក្រ ១៤រោច ខែស្រាពណ៍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៦

ក្រសួងព័ត៌មាន

GO.gov.KH

QR Code សម្រាប់ការចុះឈ្មោះ

អាគារលេខ៦២ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
Building 62, Monivong BLVD., Sangkat Srah Chork, Khan Daun Penh, Phnom Penh email: information@info.gov.kh and cabinet@info.gov.kh